**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខៈ ០៣៣/០៥ កប/ស.ជ.៣

# សេចក្តីជូនដំណឹង
## ស្តីពី
## នីតិវិធីនៃការបញ្ជាក់ភាពជាតំណាង និងតំណាងបំផុត និងការបោះឆ្នោតសម្រេចភាពជាតំណាងបំផុតរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតថ្នាក់សហគ្រាស គ្រឹះស្ថាន

សេចក្តីជូនដំណឹងនេះគឺធ្វើឡើងក្នុងគោលបំណងធ្វើអោយប្រសើរឡើងដល់ការអនុវត្តន៍នូវប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាព ដើម្បីកសាងអនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់កម្មករនិយោជិត សហជីព សហព័ន្ធសហជីពកម្មករនិយោជិត និង និយោជកនៃសហគ្រាស គ្រឹះស្ថាន ទាំងអស់អំពីនីតិវិធីទាក់ទងទៅនឹងដំណើរការនៃការដាក់ពាក្យសុំបញ្ជាក់ភាពជាតំណាង និងភាពជាតំណាងបំផុត ការជំទាស់និងការបោះឆ្នោតសំរេចភាពជាតំណាងបំផុត របស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតដូចខាងក្រោម ÷

## I- ការបញ្ជាក់អំពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត

មាត្រា២៧៧ ចំណុចទី១នៃច្បាប់ស្តីពីការងារចែងថា "១-ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៅថ្នាក់សហគ្រាស គ្រឹះស្ថានត្រូវបានទទួលស្គាល់ក្នុងក្របខ័ណ្ឌ ភូមិសាស្ត្រ ឬវិជ្ជាជីវៈ ឬក្នុងករណីចាំបាច់ទៅតាមប្រភេទដែលសហជីពបានចុះបញ្ជីធ្វើសកម្មភាព ។ ភាពជាតំណាងនេះត្រូវកំណត់តាមលក្ខណៈវិនិច្ឆ័យដូចតទៅ ÷

ក-បានចុះបញ្ជិកាត្រឹមត្រូវ ។



អាសយដ្ឋានអគារលេខ ៣, មហាវិថីសហព័ន្ធរុស្ស៊ី, សង្កាត់ទឹកល្អក់២, ខ័ណ្ឌទួលគោក, ប្រអប់សំបុត្រ P.O Box 1506ទូរស័ព្ទ និង ទូរសារ: (០២៣) ៣៥៣ ៥៣៨

ខ-មានចំនួនសមាជិកដែលមានប័ណ្ណសំគាល់សមាជិកភាពត្រឹមត្រូវច្រើនជាងគេ ។ សហជីពណា ដែលមានចំនួនសមាជិកច្រើនជាងគេក្នុងលំដាប់ថ្នាក់លេខមួយ និងលេខពីរ ត្រូវចាត់ទុកថាជាសហជីព ដែលមានភាពជាតំណាងនៅក្នុងសហគ្រាស ។ ប៉ុន្តែសហជីពណាដែលមានសមាជិកចំនួនហាសិបមួយភាគរយ "៥១%" ឡើងទៅនៃចំនួនសមាជិកសរុបរបស់សហគ្រាស ត្រូវចាត់ទុកថាជាសហជីព ដែលមានភាពជាតំណាងបំផុត ។

គ- បានទទួលប្រាក់ភាគទានយ៉ាងហោចណាស់ ៣៣%(សាមសិបបីភាគរយ នៃចំនួនសមាជិក) ។

ឃ-មានកម្មវិធី និងសកម្មភាព ដែលបង្ហាញថាសហជីពនោះមានលទ្ធភាពផ្តល់សេវាខាងវិជ្ជាជីវៈ វប្បធម៌ និងអប់រំដល់សមាជិករបស់ខ្លួនដូចមានចែងក្នុងមាត្រា២៦៦នៃច្បាប់នេះ ។ "

## A. គោលការណ៍ណែនាំ និង នីតិវិធីសម្រាប់ការដាក់ពាក្យសុំបញ្ជាក់ភាពជាតំណាង និង ភាពជាតំណាងបំផុត

១-សហជីព ដែលមានបំណងស្នើសុំការបញ្ជាក់អំពីភាពជាតំណាង ឬ តំណាងបំផុត ត្រូវដាក់ពាក្យស្នើសុំចំនួន ១៥(ដប់ប្រាំ) ច្បាប់ នៅការិយាល័យទំនាក់ទំនងវិជ្ជាជីវៈនៃនាយកដ្ឋានវិវាទការងារ នៃអគ្គនាយកដ្ឋានការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ពាក្យស្នើសុំនេះ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពី ÷

- ឈ្មោះសហជីព
- ឈ្មោះសហព័ន្ធសហជីព ដែលសហជីពនោះជាសមាជិកប្រសិនបើមាន
- ឈ្មោះ និងអាសយដ្ឋានទាក់ទងរបស់ប្រធានសហជីពនៅក្នុងសហគ្រាស គ្រឹះស្ថាន
- ឈ្មោះ និងអាសយដ្ឋានរបស់សហគ្រាស គ្រឹះស្ថាន
- វិស័យឧស្សាហកម្ម ដែលសហគ្រាសធ្វើសកម្មភាព (វិស័យកាត់ដេរ សណ្ឋាគារ ។ល។)
- ក្របខ័ណ្ឌភូមិសាស្ត្រ ឬវិជ្ជាជីវៈ ដែលមានបំណងស្នើសុំបញ្ជាក់ភាពជាតំណាង
- លេខ និងថ្ងៃ ខែ ឆ្នាំ វិញ្ញាបនប័ត្រចុះបញ្ជិកា និងការកែប្រែបន្ថែមទៀត
- ចំនួនសមាជិករបស់សហជីព និងចំនួនកម្មករនិយោជិតសរុបក្នុងក្របខ័ណ្ឌភូមិសាស្ត្រ ឬវិជ្ជាជីវៈ ដែលស្នើសុំការបញ្ជាក់ ព្រមទាំងធ្វើការប្រៀបធៀបជាភាគរយ
- ចំនួនសមាជិករបស់សហជីព ដែលបានបង់ភាគទានសហជីព និងរូបភាពបង់ភាគទាននេះ( បង់ដោយផ្ទាល់ទៅសហជីព ឬតាមរយៈការកាត់ប្រាក់ឈ្នួលដោយនិយោជក)
- កម្មវិធីការងាររបស់សហជីព ។

ទន្ទឹមនេះ សហជីពសាមីត្រូវផ្តល់នូវភស្តុតាងភ្ជាប់ជាមួយពាក្យសុំការបញ្ជាក់ដូចខាងក្រោម ÷

- សេចក្តីចម្លងវិញ្ញាបនប័ត្រចុះបញ្ជិកាសហជីព
- ភស្តុតាងនៃការកែប្រែបន្ថែមទៀត ។

២-គំរូសម្រាប់ដាក់ពាក្យសុំនេះមាននៅក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីជូនដំណឹងនេះ ហើយអាចរកបាន នៅឯការិយាល័យទំនាក់ទំនងវិជ្ជាជីវៈនៃនាយកដ្ឋានវិវាទការងារ អគ្គនាយកដ្ឋានការងារ ឬតាមរយៈសហព័ន្ធសហជីព។

B- **គោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ការទទួលពាក្យសុំបញ្ជាក់ភាពជាតំណាង និងភាពជាតំណាងបំផុត**

១-នៅពេលទទួលបានពាក្យសុំបញ្ជាក់ភាពជាតំណាង ឬភាពជាតំណាងបំផុត របស់សហជីពរួចហើយ ការិយាល័យទំនាក់ទំនងវិជ្ជាជីវៈត្រូវចេញនូវបង្កាន់ដៃបញ្ជាក់ទទួលពាក្យសុំអោយសហជីពនោះវិញ។ បង្កាន់ដៃទទួលពាក្យសុំនេះត្រូវបញ្ជាក់ថាពាក្យសុំនោះមានឯកសារ ដែលតម្រូវឱ្យភ្ជាប់មកជាមួយគ្រប់គ្រាន់ហើយ ។ បង្កាន់ដៃនោះក៏ត្រូវកំណត់អំពីកាលបរិច្ឆេទ នៃការណាត់ជួបជាមួយការិយាល័យទំនាក់ទំនងវិជ្ជាជីវៈ ដើម្បីពិនិត្យពាក្យសុំឡើងវិញ។

២-ក្រោយ៧(ប្រាំពីរ)ថ្ងៃគិតចាប់ពីថ្ងៃដាក់ពាក្យសុំអ្នកដាក់ពាក្យសុំត្រូវទៅជួបមន្ត្រីនៃការិយាល័យទំនាក់ទំនងវិជ្ជាជីវៈដើម្បីទទួលដំណឹងអំពីភាពសមស្រប ឬមិនសមស្របនៃសំណុំលិខិតស្នើសុំរបស់ខ្លួន។ ក្នុងករណីដែលសំណុំលិខិតស្នើសុំនោះមានភាពមិនសមស្របត្រង់ចំណុចណាមួយ ស្ថាបនិកនៃសាមីអង្គការវិជ្ជាជីវៈត្រូវទទួលយកសំណុំលិខិតនោះទៅធ្វើការកែសម្រួល ឬបំពេញបន្ថែមឱ្យបានត្រឹមត្រូវរួចហើយទើបយកទៅដាក់ជូនជាថ្មីទៀតនៅការិយាល័យទំនាក់ទំនងវិជ្ជាជីវៈ។ រយៈពេលនៃការទទួលយកសំណុំលិខិតរបស់ខ្លួនទៅកែសម្រួល ឬបំពេញបន្ថែមនោះ មិនគិតចូលក្នុងថិរវេលានៃការពិនិត្យពាក្យស្នើសុំទាំងឡាយខាងលើនោះឡើយ ។ ករណី ដែលសំណុំលិខិតស្នើសុំត្រូវបានពិនិត្យឃើញមានភាពមិនសមស្រប ហើយម្ចាស់សំណុំលិខិតមិនបានទៅជួបមន្ត្រីនៃការិយាល័យទំនាក់ទំនងវិជ្ជាជីវៈទេ មន្ត្រីនោះត្រូវផ្ញើសំណុំលិខិតនោះត្រឡប់ទៅម្ចាស់ដើមវិញ។

C- **គោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ការផ្សព្វផ្សាយ ការបញ្ជាក់ភាពជាតំណាង និងភាពជាតំណាងបំផុត**

១-នៅក្រោយពេលទទួលបានពាក្យស្នើសុំបញ្ជាក់ភាពជាតំណាងនិងភាពជាតំណាងបំផុត ដែលមានលក្ខណៈពេញលេញ និងត្រឹមត្រូវហើយនោះក្រសួងនឹងជូនដំណឹងទៅដល់អ្នកគ្រប់គ្រងសហគ្រាស គ្រឹះស្ថាននិងសហជីពដទៃទៀតទាំងអស់នៅក្នុងសហគ្រាស គ្រឹះស្ថាននោះអំពីការដាក់ពាក្យសុំខាងលើ។ ក្រសួងក៏នឹងផ្ញើលិខិតអនុសិដ្ឋ ឬប្រគល់ដោយផ្ទាល់ដៃទៅឱ្យនិយោជកនៃសហគ្រាស គ្រឹះស្ថាននោះដើម្បីណែនាំឱ្យនិយោជកបិទប្រកាសពាក្យសុំបញ្ជាក់ភាពជាតំណាង និងភាពជាតំណាងបំផុតនេះនៅលើក្តារខៀនជូនដំណឹងនៅក្នុងសហគ្រាស គ្រឹះស្ថានជាសាធារណៈ។ ការបិទប្រកាសនេះត្រូវមានថិរវេលាយ៉ាងតិច ១៥(ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតពីក្រសួង។ ក្នុងករណីដែលនិយោជកពុំបានបិទផ្សាយទេនោះសហជីពសាមីអាចដាក់ពាក្យបណ្តឹងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីធ្វើការដោះស្រាយ។

២-ក្រសួងនឹងផ្ញើលិខិតអនុសិដ្ឋ ឬប្រគល់ដោយផ្ទាល់ដៃទៅឱ្យនិយោជក និងសហជីព ដែលជាសមាជិកពេញសិទ្ធិរបស់គណៈកម្មការប្រឹក្សាការងារ។ លិខិតស្នើសុំសេចក្តីអង្កេតនេះ ត្រូវបញ្ជាក់ពីកាលបរិច្ឆេទនៃការចេញ

សេចក្តីបញ្ជាក់ភាពជាតំណាង ឬភាពជាតំណាងបំផុត ដែលនឹងចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យទៅសហជីព ប្រសិនបើពុំមានការតវ៉ា ឬជំទាស់ណាមួយទេនោះ ។ គោលបំណងនៃលិខិតនេះ គឺគ្រាន់តែជាការជូនដំណឹងដល់និយោជក និងសហជីព ដែលជាសមាជិករបស់គណៈកម្មការប្រឹក្សាការងារ ដើម្បីផ្តល់ការអង្កេតតែប៉ុណ្ណោះ ប៉ុន្តែពុំមានបំណងសុំនូវការអនុម័តយល់ព្រមពីពួកគាត់ឡើយ ។

**D- គោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ការបញ្ជាក់ភាពជាតំណាង និងភាពតំណាងបំផុត**

១-រយៈពេលកំណត់សម្រាប់ដំណើរការចេញសេចក្តីបញ្ជាក់ភាពជាតំណាង ឬភាពជាតំណាងបំផុតរបស់សហជីពកម្មករនិយោជិតគឺ ៦០(ហុកសិប) ថ្ងៃ គិតចាប់តាំងពីពេលទទួលពាក្យសុំ ។

២-ក្នុងករណីពិនិត្យឃើញថាមានការយឺតយ៉ាវក្នុងការចេញលិខិតបញ្ជាក់អំពីភាពជាតំណាងអង្គការវិជ្ជាជីវៈ នៃកម្មករនិយោជិតខុសពីថិរវេលាខាងលើ ម្ចាស់សំណុំរឿងអាចធ្វើការតវ៉ាជាលាយល័ក្ខណ៍អក្សរទៅនាយកដ្ឋានវិវាទការងារ ។ ក្រោយពីដាក់ពាក្យតវ៉ានេះរយៈពេល២(ពីរ)សប្តាហ៍បើគ្មានការបំភ្លឺសមស្របពីនាយកដ្ឋានវិវាទការងារទេ ម្ចាស់សំណុំរឿងអាចធ្វើការតវ៉ាដោយផ្ទាល់ទៅអគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ឬទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

៣-ពុំមានការបង់ប្រាក់កាសឡើយចំពោះការបញ្ជាក់ភាពជាតំណាង ឬភាពជាតំណាងបំផុត ។

**E- គោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ការជំទាស់ទៅនឹងការបញ្ជាក់ភាពជាតំណាងបំផុត**

១-នៅក្នុងករណីពុំមានការជំទាស់ណាមួយ ដែលផ្អែកលើមូលហេតុ ឬភស្តុតាងដូចមានរៀបរាប់ខាងក្រោមធ្វើឡើងក្នុងរយៈពេល ១៥(ដប់ប្រាំ) ថ្ងៃ គិតចាប់ពីការចុះកាលបរិច្ឆេទនៃលិខិត ដែលបានផ្ញើរទៅសហគ្រាស គ្រឹះស្ថាន និងគណៈកម្មការប្រឹក្សាការងារទេនោះ ការិយាល័យទំនាក់ទំនងវិជ្ជាជីវៈ នឹងរៀបចំសំណុំឯកសារជូនថ្នាក់ដឹកនាំក្រសួងដើម្បីចេញសេចក្តីបញ្ជាក់ភាពជាតំណាង ឬភាពជាតំណាងបំផុតដល់សហជីព ដែលបានដាក់ពាក្យសុំ និងជូនដំណឹងទៅសហជីព និងអ្នកគ្រប់គ្រងសហគ្រាស គ្រឹះស្ថាន តាមរយៈលិខិតអនុសិដ្ឋ ឬប្រគល់ដោយផ្ទាល់ ។

២- រាល់ការជំទាស់ត្រូវបំពេញនៅក្នុងគំរូសម្រាប់ការជំទាស់ និងត្រូវដាក់បញ្ចូលនូវព័ត៌មានទាំងឡាយដូចខាងក្រោម ÷

ក) ឈ្មោះរូបវន្ត ឬ នីតិបុគ្គល ដែលដាក់ពាក្យជំទាស់ ។

ខ) ផលប្រយោជន៍ស្របច្បាប់របស់ភាគីជំទាស់ ដែលមាននៅក្នុងពាក្យសុំបញ្ជាក់ភាពជាតំណាងបំផុត ។

គ) មូលហេតុ ឬហេតុផលនៃការជំទាស់ ។

ឃ) ភស្តុតាងនៃការជំទាស់ ។

គំរូសម្រាប់ការជំទាស់មាននៅក្នុងឧបសម្ព័ន្ធទី២ នៃសេចក្តីជូនដំណឹងនេះ ។

៣-ការជំទាស់ទាំងឡាយត្រូវតែផ្អែកលើហេតុផលដូចខាងក្រោម ÷

ក) សហជីពដាក់ពាក្យសុំនោះ ពុំមែនជាសហជីព ដែលមានភាពជាតំណាងបំផុត ។

ខ) សហជីពដាក់ពាក្យសុំនោះបានក្លែងបន្លំពាក្យសុំរបស់ខ្លួន ។

គ) និយោជកបានប្រើឥទ្ធិពលរបស់ខ្លួនមកលើសហជីពដាក់ពាក្យសុំ ដែលធ្វើឱ្យសហជីពនោះមិនមានភាពឯករាជ្យពីនិយោជក ។

៤-សហព័ន្ធសហជីពណាមួយ ដែលមិនមានសហជីពរបស់ខ្លួននៅក្នុងសហគ្រាស គ្រឹះស្ថាន ឬ សហជីពដែលមិនទាន់បានចុះបញ្ជិកានៅក្នុងសហគ្រាស គ្រឹះស្ថាន មិនអាចធ្វើការជំទាស់ទៅលើការដាក់ពាក្យសុំភាពជាតំណាងបំផុតរបស់សហជីពសាមីឡើយ ។

៥-រាល់ការជំទាស់ត្រូវតែមានភស្តុតាងដូចជាសក្ខីភាពដែលផ្តល់អោយដោយកម្មករនិយោជិត( ចុះហត្ថលេខា ឬផ្តិតមេដៃ) ឬ ឯកសារផ្សេងៗ ។

៦-សហជីព និងនិយោជក អាចមកកាន់ការិយាល័យទំនាក់ទំនងវិជ្ជាជីវៈដោយផ្ទាល់ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដើម្បីទទួលព័ត៌មានថាតើមានអ្នកដាក់ពាក្យប្តឹងជំទាស់ដែរឬទេ ។

៧-នៅមុនពេលទទួលយកការជំទាស់ ក្រសួងនឹងជួបជាមួយភាគីពាក់ព័ន្ធដើម្បីត្រួតពិនិត្យ និងធ្វើការផ្ទៀងផ្ទាត់ភស្តុតាងទាំងឡាយ ដែលបានផ្តល់ឱ្យ ។

៨-ប្រសិនបើការជំទាស់ត្រូវបានទទួលយក ក្រសួងនឹងជូនដំណឹងទៅនិយោជក និងសហជីពពាក់ព័ន្ធតាមលិខិតអនុសិដ្ឋ ឬប្រគល់ដោយផ្ទាល់ដៃ ដោយមានការពន្យល់ពីហេតុផលនៃការទទួលយកការជំទាស់នោះ ។ ប្រសិនបើក្រសួងបដិសេធការស្នើសុំជំទាស់ណាមួយនោះ ក្រសួងនឹងចេញសេចក្តីបញ្ជាក់ដល់សហជីព ដែលដាក់ពាក្យសុំជំទាស់នោះ ព្រមទាំងមានការពន្យល់ពីហេតុផលផងដែរ ។

៩-សហជីព ដែលត្រូវបានគេជំទាស់ នឹងត្រូវផ្តល់ឱ្យក្រសួងនូវរាល់ភស្តុតាង ដែលប្រើជាមូលដ្ឋាន ក្នុងការការពារនៃការជំទាស់នោះ ។

១០-ក្រសួងមានសិទ្ធិស្នើសុំនូវព័ត៌មានបន្ថែមពីនិយោជកដូចជាចំនួនកម្មករសរុប ដែលកំពុងធ្វើការនាពេលបច្ចុប្បន្ននៅក្នុងសហគ្រាស គ្រឹះស្ថាន ឬផ្នែកណាមួយនៃសហគ្រាស គ្រឹះស្ថាន ច្បាប់ចម្លងនៃបញ្ជីបើកប្រាក់ឈ្នួល ដែលមានការកាត់ភាគទានសហជីព ដូចដែលបានស្នើឡើងដោយសហជីព ឬក៏ព័ត៌មានពាក់ព័ន្ធ ទាំងឡាយផ្សេងៗទៀតដែលទាក់ទិនទៅនឹងកាលៈទេសៈ ដែលអាចកើតមានដូចខាងក្រោម ÷

-បញ្ជីបើកប្រាក់ឈ្នួលរបស់កម្មករសរុប ដែលកំពុងធ្វើការនៅក្នុងសហគ្រាស គ្រឹះស្ថានបច្ចុប្បន្ន

-ប្រសិនបើមានការជំទាស់ណាមួយត្រូវបានធ្វើឡើងដោយសហជីពដទៃទៀត ឬដោយរូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានការពាក់ព័ន្ធទៅនឹងព័ត៌មាននៅក្នុង ឬក៏ភស្តុតាង ដែលបានដាក់ភ្ជាប់មកជាមួយនឹងគំរូដាក់ពាក្យសុំ ដែលមានហេតុផលដូចបានបញ្ជាក់នៅក្នុងចំណុចទី ២ នៃគោលការណ៍ណែនាំ និង

- ក្នុងករណី ដែលមានការខុសប្លែកគ្នាត្រូវបានរកឃើញទាក់ទងទៅនឹងព័ត៌មាន ឬភស្តុតាងដូចបានលើកឡើងខាងលើ ដែលជាលទ្ធផលនៃការពិនិត្យពិច័យរបស់នាយកដ្ឋានវិវាទការងារ ឬការិយាល័យទំនាក់ទំនងវិជ្ជាជីវៈ ។

១១-ក្នុងករណីដែលការជំទាស់ទៅលើភាពជាតំណាងបំផុតត្រូវបានទទួលដោយក្រសួង សហជីព ដែលត្រូវគេជំទាស់ ឬសហព័ន្ធរបស់ខ្លួន អាចស្នើសុំក្រសួងដើម្បីរៀបចំការបោះឆ្នោត ។ នៅក្នុងចន្លោះពេលពីរសប្តាហ៍ បន្ទាប់ពីបានទទួលការស្នើសុំពីសហជីពឱ្យមានការបោះឆ្នោត ក្រសួងត្រូវជួបជាមួយភាគី ដើម្បីពិភាក្សាលើដំណើរការរៀបចំការបោះឆ្នោត និងកំណត់កាលបរិច្ឆេទនៃការបោះឆ្នោត ។

## II. ដំណើរការនៃការរៀបចំ និងការប្រព្រឹត្តទៅនៃការបោះឆ្នោតដើម្បីកំណត់ភាពជាតំណាងបំផុត

### A- ការត្រៀមរៀបចំការបោះឆ្នោត

១-នៅក្នុងចន្លោះពេលយ៉ាងយូរ១៥(ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីទទួលបានការស្នើសុំរបស់សហជីព ការិយាល័យទំនាក់ទំនងវិជ្ជាជីវៈនឹងអញ្ជើញភាគីពាក់ព័ន្ធរួមទាំងតំណាងសហជីពដទៃទៀតនៅក្នុងសហគ្រាស គ្រឹះស្ថាន តំណាងសហព័ន្ធសហជីព និងនិយោជកដើម្បីពិភាក្សាអំពីការរៀបចំការបោះឆ្នោត រួមទាំងពេលវេលា និងទីកន្លែងនៃការបោះឆ្នោតផងដែរ ។

ក) ក្នុងករណី ដែលសហជីពដាក់ពាក្យសុំធ្វើការបោះឆ្នោតអវត្តមាន ដោយគ្មានការជូនដំណឹង និងគ្មានមូលហេតុសមស្របនោះទេ សហជីពនោះត្រូវចាត់ទុកថាបានបោះបង់ការស្នើសុំធ្វើការបោះឆ្នោត និងការស្នើសុំភាពជាតំណាង ។

ខ) ក្នុងករណី ដែលភាគីជំទាស់អវត្តមានមិនបានចូលរួមក្នុងកិច្ចប្រជុំតាមការអញ្ជើញរបស់ក្រសួងដោយគ្មានការជូនដំណឹងមុន និងគ្មានមូលហេតុសមស្របត្រូវចាត់ទុកថាភាគីនោះឯកភាពតាមការសម្រេចរបស់អង្គប្រជុំ ។

គ) កិច្ចប្រជុំនេះនឹងត្រូវបង្កើតឡើងនូវគណៈកម្មការរៀបចំ និងត្រួតពិនិត្យការបោះឆ្នោតមួយ (ដូចមានរៀបរាប់លំអិតនៅខាងក្រោម) ។

២-នៅក្នុងកិច្ចប្រជុំនេះ និយោជកត្រូវយកបញ្ជីឈ្មោះរបស់កម្មករនិយោជិត ដែលមានសិទ្ធិបោះឆ្នោតចំនួន ៣ ច្បាប់ គឺ ១ ច្បាប់ សម្រាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ១ ច្បាប់ សម្រាប់សហជីព នៅក្នុងសហគ្រាស គ្រឹះស្ថាន និង១ ច្បាប់ ទៀតសម្រាប់សហព័ន្ធសហជីព ។ សហជីពអាចត្រួតពិនិត្យនិងស្នើធ្វើការផ្លាស់ប្តូរបញ្ជីឈ្មោះនេះ ក្នុងរយៈពេល៥ថ្ងៃនៅមុនកិច្ចប្រជុំ ។ បន្ទាប់មកគណៈកម្មការរៀបចំការបោះឆ្នោតត្រូវជួបប្រជុំដើម្បីពិនិត្យមើលសំណើសុំផ្លាស់ប្តូរ និងអនុម័តលើបញ្ជីឈ្មោះចុងក្រោយអោយបានមុន៧ថ្ងៃ នៅមុនការបោះឆ្នោត ។

៣-នៅពេលត្រូវបានព្រមព្រៀងដោយគ្រប់ភាគីពាក់ព័ន្ធរួចហើយអំពីទីកន្លែង កាលបរិច្ឆេទ និងពេលវេលា ក្រសួងនឹងរៀបចំកំណត់ហេតុនៃកិច្ចប្រជុំ ដែលនឹងត្រូវចុះហត្ថលេខាដោយភាគីទាំងអស់ ហើយផ្តល់ឱ្យភាគីទាំងនោះនូវច្បាប់ចម្លងនៃកំណត់ហេតុកិច្ចប្រជុំនោះ និងជូនដំណឹងអំពីការងាររៀបចំទាំងឡាយ ដែលចាំបាច់សម្រាប់ដំណើរការនៃការប្រព្រឹត្តទៅនៃការបោះឆ្នោត ។

**B. ការរៀបចំការបោះឆ្នោត**

១-យោងតាមប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២ សហជីពទាំងឡាយដែលមានបំណងចង់ចូលរួមនៅក្នុងការបោះឆ្នោតនៅក្នុងសហគ្រាស គ្រឹះស្ថាន ក៏ដូចជា និយោជក នឹងត្រូវបានអញ្ជើញដើម្បីធ្វើការពិគ្រោះយោបល់អំពីនីតិវិធី ពេលវេលា និងទីកន្លែងនៃការបោះឆ្នោត ។ ការរៀបចំ និងការត្រួតពិនិត្យការបោះឆ្នោតអាចនឹងត្រូវប្រគល់ជូនតតិយជន ឬ ស្ថាប័នសាធារណៈ ឬ ឯកជន ដែលស្ម័គ្រចិត្តទទួលរៀបចំ និងត្រួតពិនិត្យការបោះឆ្នោតនេះប្រសិន បើភាគីទាំងសងខាងយល់ព្រម ។ នៅក្នុងករណីនេះតតិយជន ត្រូវបំពេញភារកិច្ចរបស់ខ្លួនទៅតាមនីតិវិធីដូចមានរៀបរាប់ខាងក្រោម ។ ក្នុងករណី ដែលពុំមាននរណាម្នាក់ទទួលយកនូវការទទួលខុសត្រូវបំពេញកិច្ចការនេះទេនៅក្នុងកិច្ចប្រជុំលើកទី១ របស់ភាគីដូចមានរៀបរាប់ខាងលើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអ្នកទទួលបន្ទុកបង្កើតនូវគណៈកម្មការមួយទទួលខុសត្រូវរៀបចំការបោះឆ្នោត (គណៈកម្មការរៀបចំ និងត្រួតពិនិត្យការបោះឆ្នោត) ដែលនឹងរួមមានសមាសភាព ដូចតទៅ ÷

-តំណាងពីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ១ រូប ជាប្រធាន

-តំណាងចំនួន ១ រូប មកពីសហព័ន្ធសហជីពនីមួយៗ និងតំណាងចំនួន ៣ រូប ពីសហជីពនីមួយៗដែលពាក់ព័ន្ធ ។

២-តួនាទីរបស់គណៈកម្មការរៀបចំ និងត្រួតពិនិត្យការបោះឆ្នោតមានដូចតទៅ ÷

-ពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីឈ្មោះអ្នកបោះឆ្នោត

- រៀបចំទីកន្លែង និងកាលបរិច្ឆេទនៃការបោះឆ្នោត

- សម្របសម្រួលដំណើរការបោះឆ្នោត

- ពន្យល់អំពីនីតិវិធីនៃការបោះឆ្នោត ពិនិត្យដំណើរការបោះឆ្នោត និងប្រកាសលទ្ធផលនៃការបោះឆ្នោត ។

៣-អ្នកដែលមានសិទ្ធិបោះឆ្នោត និងបញ្ជីឈ្មោះអ្នកបោះឆ្នោត

កម្មករនិយោជិតទាំងអស់ ដែលធ្វើការទៀងទាត់នៅក្នុងសហគ្រាស គ្រឹះស្ថានយ៉ាងតិចចំនួន ៣(បី) ខែរាប់បញ្ចូលទាំងថ្ងៃចូលសាកល្បងការងារផង មានសិទ្ធិចូលរួមក្នុងការបោះឆ្នោត ។

៤-ទីកន្លែងនៃការបោះឆ្នោត

ការបោះឆ្នោតអាចធ្វើឡើងនៅក្នុង ឬនៅក្រៅសហគ្រាស គ្រឹះស្ថាន ទៅតាមកិច្ចព្រមព្រៀងនៃកិច្ច

ប្រជុំពិភាក្សា ។ ការបោះឆ្នោតត្រូវធ្វើនៅកន្លែងធ្វើការ ប្រសិនបើមានការយល់ព្រមពីនិយោជក ឬនៅទីណាជិតកន្លែងធ្វើការ ប្រសិនបើគ្មានការយល់ព្រមពីនិយោជក ។

៥-កាលបរិច្ឆេទ និងពេលវេលានៃការបោះឆ្នោត

កាលបរិច្ឆេទ និងពេលវេលានៃការបោះឆ្នោតត្រូវកំណត់ បន្ទាប់ពីមានការព្រមព្រៀងដូចមានចែងក្នុងកថាខ័ណ្ឌ១ ខាងលើ ។ ការបោះឆ្នោតត្រូវធ្វើក្នុងពេលម៉ោងធ្វើការប្រសិនបើមានការយល់ព្រមពីនិយោជក ។ ការបោះឆ្នោតត្រូវធ្វើនៅមុន ឬក្រោយពេលម៉ោងធ្វើការ ប្រសិនបើមិនមានការយល់ព្រមពីនិយោជកឱ្យធ្វើការបោះឆ្នោតក្នុងម៉ោងធ្វើការទេនោះ ។

៦-ការជូនដំណឹងដល់កម្មករនិយោជិត

កាលបរិច្ឆេទ និងពេលវេលានៃការបោះឆ្នោតត្រូវជូនដំណឹងដល់កម្មករនិយោជិតយ៉ាងតិច ០៧ ថ្ងៃមុនថ្ងៃបោះឆ្នោត ។ ការជូនដំណឹងនេះត្រូវបិទនៅក្នុងទីកន្លែង ដែលងាយស្រួលចេញចូលមើលនៅក្នុងសហគ្រាស គ្រឹះស្ថាន យ៉ាងហោចណាស់ ០៧( ប្រាំពីរ ) ថ្ងៃ បន្តបន្ទាប់គ្នានៅមុនការបោះឆ្នោត ។

៧-សន្លឹកឆ្នោត និងការគូសសន្លឹកឆ្នោត

សន្លឹកឆ្នោតត្រូវមានឈ្មោះសហជីពទាំងអស់ ដែលត្រូវចូលរួមក្នុងការបោះឆ្នោតព្រមទាំងមានបិទរូបថតប្រធានសហជីព ដែលនៅជាប់មានប្រអប់សម្រាប់គូស ។ អ្នកមានសិទ្ធិបោះឆ្នោត ត្រូវគូសតែប្រអប់មួយគត់ដើម្បីចង្អុលបង្ហាញថាតើសហជីពមួយណា ដែលពួកគេបោះឆ្នោតឱ្យ ។ត្រូវមានប្រអប់មួយទៀត ដែលមានសរសេរអក្សរថា "មិនមានសហជីពណាមួយ" កម្មករនិយោជិតត្រូវគូសប្រអប់នេះ ប្រសិនបើគាត់មិនមានបំណងឱ្យសហជីពណាមួយនៃសហជីព ដែលចូលរួមបោះឆ្នោតនេះធ្វើជាតំណាងរបស់គាត់ ។ សន្លឹកឆ្នោតមិនត្រូវចុះហត្ថលេខា ឬ គូសសញ្ញាអ្វីក្រៅពីសញ្ញា ដែលណែនាំ បើពុំដូច្នោះទេត្រូវចាត់ទុកជាមោឃៈ ។

៨-តួនាទីរបស់អ្នកសង្កេតការណ៍

អ្នកសង្កេតការណ៍មកពីអង្គការជាតិ និងអន្តរជាតិ តាមការស្នើសុំពីភាគីពាក់ព័ន្ធណាមួយអាចសង្កេតការណ៍លើភាពត្រឹមត្រូវនៃការបោះឆ្នោត ។

**C-ទីកន្លែងបោះឆ្នោត នីតិវិធី និងសន្លឹកឆ្នោត**

១-នៅក្នុងទីកន្លែងបោះឆ្នោត នឹងមានតុយ៉ាងហោចណាស់ចំនួន២ និង ហិបឆ្នោត១ ។ ប្រអប់ឆ្នោតត្រូវដាក់នៅលើតុណាមួយ ហើយកម្មករនិយោជិតត្រូវទទួលសន្លឹកឆ្នោតរបស់គេពីតុមួយទៀត ។ អ្នកសង្កេតការណ៍ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និយោជក សហជីព  អង្គការជាតិ និងអន្តរជាតិ ប្រសិនបើមានការអញ្ជើញអាចអង្គុយនៅផ្នែកម្ខាងនៃតុទាំងពីរ ។ សមាជិករបស់គណៈកម្មការជាធម្មតានឹងដើរតួនាទីជាអ្នកសង្កេតការណ៍ ។ អ្នកសង្កេតការណ៍នីមួយៗនឹងត្រូវគេផ្តល់ឱ្យនូវប័ណ្ណសំគាល់ខ្លួន ។ មានតែតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈប៉ុណ្ណោះ ដែលអាចនិយាយជាមួយនឹងកម្មករនិយោជិតបាននៅក្នុងកំឡុងពេលបោះឆ្នោត ។

២-កម្មករនិយោជិតត្រូវដើរទៅកាន់គុហោះឆ្នោតជាជួរតាមលំដាប់លំដោយ ។

៣-កម្មករនិយោជិតត្រូវប្រាប់ឈ្មោះរបស់គេទៅឱ្យអ្នកសង្កេតការណ៍ម្នាក់ ដែលត្រូវផ្ទៀងផ្ទាត់មើលឱ្យច្បាស់ថាឈ្មោះរបស់ពួកគាត់មាននៅក្នុងបញ្ជីបោះឆ្នោត ។ អ្នកសង្កេតការណ៍នឹងជម្រាបប្រាប់ទៅតំណាងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈថាតើឈ្មោះរបស់កម្មករនិយោជិតរូបនោះមាននៅក្នុងបញ្ជីបោះឆ្នោតឬយ៉ាងណា ។

៤-នៅក្រោយពេល ដែលឈ្មោះកម្មករនិយោជិតនោះត្រូវបានបញ្ជាក់ថាមាននៅក្នុងបញ្ជីបោះឆ្នោតរួចហើយកម្មករនិយោជិតនឹងត្រូវទទួលបាននូវសន្លឹកឆ្នោតពីគណៈកម្មការរៀបចំ និងត្រួតពិនិត្យការបោះឆ្នោត ។

៥-កម្មករនិយោជិតត្រូវគូសសន្លឹកឆ្នោតជាមួយនឹងសញ្ញា " ✓ " ឬ " X " តែម៉្យាងប៉ុណ្ណោះនៅក្នុងប្រអប់ ដែលនៅជាប់នឹងសហជីពដែលខ្លួនគាំទ្រ ឬនៅជាប់នឹងប្រអប់ ដែលសរសេរថា " មិនមានសហជីពណាមួយ " ប្រសិនបើកម្មករនិយោជិតរូបនោះមិនមានបំណងឱ្យសហជីពណាមួយធ្វើជាតំណាងរបស់គាត់ ។ បត់សន្លឹកឆ្នោតរួចទំលាក់ដោយផ្ទាល់ទៅក្នុងប្រអប់ឆ្នោត ។ មិនត្រូវចុះហត្ថលេខា ឬគូសសញ្ញាអ្វីក្រៅពីនេះឡើយ ។ ពុំមាននរណាម្នាក់ត្រូវបានអនុញ្ញាតឱ្យប៉ះពាល់សន្លឹកឆ្នោតឡើយ ។

**D- តួនាទីរបស់សហជីព និងនិយោជកនៅមុនពេលបោះឆ្នោត**

១-គ្រប់សហជីពទាំងអស់ ដែលបានចុះបញ្ជិកានៅក្នុងសហគ្រាស គ្រឹះស្ថាន នៅពេលមានការបោះឆ្នោតអាចធ្វើការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងហើយនិងនីតិវិធីនៃការបោះឆ្នោតដល់សមាជិករបស់ខ្លួននៅក្នុងម៉ោងធ្វើការប្រសិនបើមានការយល់ព្រមពីនិយោជក ឬនៅក្រៅម៉ោងធ្វើការប្រសិនពុំមានការយល់ព្រមពីនិយោជក ។

២-រាល់ទង្វើដូចមានរៀបរាប់ខាងក្រោម ត្រូវបានហាមឃាត់ចំពោះតំណាងសហជីព ក៏ដូចតំណាងនិយោជកនៅមុន និងក្នុងកំឡុងពេលនៃការបោះឆ្នោត ព្រោះថាទង្វើទាំងនេះអាចធ្វើឱ្យលទ្ធផលនៃការបោះឆ្នោតក្លាយទៅជាមោឃៈ ឬក៏មានការដាក់ទណ្ឌកម្មសមស្របដែលមានចែងនៅក្នុងច្បាប់ ។ ទង្វើទាំងនោះមានដូចតទៅ÷

ក) គំរាមកំហែងពីការបាត់បង់ការងារ ឬផលប្រយោជន៍ផ្សេងៗ ដែលជះឥទ្ធិពលដល់ការបោះឆ្នោតរបស់កម្មករ ។

ខ) សន្យា ឬតម្លើងតួនាទី តម្លើងប្រាក់ឈ្នួល ឬផលប្រយោជន៍ដទៃទៀត ដែលជះឥទ្ធិពលដល់ការបោះឆ្នោតរបស់កម្មករ ។

គ) ទាមទារ ឬសូកប៉ាន់ ឬផ្តល់ជាសំណូកដទៃទៀត ដែលជះឥទ្ធិផលដល់ការបោះឆ្នោតរបស់កម្មករ ។

ឃ) គំរាមកំហែងប្រើកំលាំងកាយ ឬអំពើហឹង្សាដែលជះឥទ្ធិពល ឬបង្កអោយមានឥទ្ធិពលដល់ការបោះឆ្នោតរបស់កម្មករ ។

ε- ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផល

១-ភ្លាមៗបន្ទាប់ពីការបោះឆ្នោតត្រូវបានបញ្ចប់ ហិបឆ្នោតនិងត្រូវប្រមូលផ្តុំនៅទីកន្លែងមួយ ដែលបានកំណត់ដោយគណៈកម្មាការរៀបចំ និងត្រួតពិនិត្យការបោះឆ្នោត ។

២-បន្ទាប់មកហិបឆ្នោតត្រូវបានបើកនៅចំពោះមុខគណៈកម្មការរៀបចំបោះឆ្នោត និងអ្នកសង្កេតការណ៍ផ្សេងៗទៀត ដែលភាគីបានព្រមព្រៀង ។ សន្លឹកឆ្នោតត្រូវរាប់ជាសាធារណៈដោយគណៈកម្មការរៀបចំ និងត្រួតពិនិត្យការបោះឆ្នោតនៅក្រោមការចាត់ចែងរបស់តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

៣-នៅក្នុងករណី ដែលការរាប់សន្លឹកឆ្នោតមិនអាចធ្វើទៅបានដោយសារមូលហេតុពេលវេលា ឬមូលហេតុផ្សេងទៀត គណៈកម្មការរៀបចំ និងត្រួតពិនិត្យការបោះឆ្នោតត្រូវរក្សាទុកហិបឆ្នោតនៅកន្លែងមានសុវត្ថិភាព ចាក់សោរ និងផ្តុំបេ ដោយមានចុះហត្ថលេខាដោយគណៈកម្មការ ។

៤-សរសេរឈ្មោះសហជីព ដែលបានចូលរួមនៅក្នុងការបោះឆ្នោតនៅលើក្តារខៀន ។ សន្លឹកឆ្នោតត្រូវរាប់ចេញពីសន្លឹកឆ្នោត ដែលយកជាបានការ និងគូសលទ្ធផលទទួលបានទៅតាមឈ្មោះសហជីព ដែលបានចូលរួម ។

៥-លទ្ធផលត្រូវប្រកាសដោយប្រធានគណៈកម្មការរៀបចំ និងត្រួតពិនិត្យការបោះឆ្នោតភ្លាមៗក្រោយពេលការរាប់សន្លឹកឆ្នោតត្រូវបានបញ្ចប់ ហើយប្រកាសសហជីព ដែលបានឈ្នះក្នុងការបោះឆ្នោតជាសហជីពមានភាពជាតំណាងបំផុត ។ សន្លឹកឆ្នោតទាំងបានការ និងមិនបានការត្រូវរក្សាទុកដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យបានយ៉ាងហោចណាស់រយៈពេល ៩០(កៅសិប) ថ្ងៃ ក្រោយពីការបោះឆ្នោត ។

៦-ក្រសួងនឹងចេញលិខិតបញ្ជាក់ភាពជាតំណាងបំផុតនៅក្នុងរយៈពេល១៥(ដប់ប្រាំ) ថ្ងៃ ក្រោយពេលប្រកាសលទ្ធផលនៃការបោះឆ្នោត ។ សហជីព ដែលមានសមាជិកភាគតិច និងនិយោជក ត្រូវគោរពលទ្ធផលនៃការបោះឆ្នោត និងភាពជាតំណាងបំផុតនៃសហជីព ដែលមានសមាជិកភាគច្រើន ។

៧-រាល់ការធ្វើឧបាស្រ័យទាក់ទងដល់ភាពត្រឹមត្រូវនៃការបោះឆ្នោត ឬលទ្ធផលនៃការបោះឆ្នោតត្រូវតែដាក់ជូនទៅតុលាការមានសមត្ថកិច្ចនៅក្នុងពេល ៨(ប្រាំបី) ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសលទ្ធផល ។ ម្ចាស់បណ្តឹងត្រូវផ្ញើនូវច្បាប់ចម្លងនៃពាក្យបណ្តឹងទៅតុលាការនេះទៅឱ្យនាយកដ្ឋានវិវាទការងារ និងសហជីព ដែលបានឈ្នះនៅក្នុងការបោះឆ្នោតជ្រាបជាព័ត៌មាន ។

៨-ការធ្វើឧបាស្រ័យនេះមិនមានផលធ្វើឱ្យផ្អាកការអនុវត្តន៍លទ្ធផលនៃការបោះឆ្នោតឡើយ ។

## III. ការប្រមូល និងការចែកចាយទិន្នន័យ

ទិន្នន័យទាំងអស់ ដែលទាក់ទងនឹងការចុះបញ្ជិកាអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត ការដាក់ពាក្យសុំ និង ការបញ្ជាក់ភាពជាតំណាងបំផុត ឬក៏ការជំទាស់ណាមួយទៅនឹងការដាក់ពាក្យសុំនេះ ប្រសិនបើមាននិងរួម

ទាំងលទ្ធផលនៃការបោះឆ្នោតនឹងត្រូវបានកត់ត្រាទុកនៅក្នុងប្រព័ន្ធទិន្នន័យស្ថិតិ រួចបោះពុម្ព និង ចែកចាយទៅឱ្យភាគីពាក់ព័ន្ធទាំងអស់នៅរៀងរាល់បំណាច់ត្រីមាស (៣ ខែ ម្តង) និងនៅបំណាច់ឆ្នាំនីមួយៗ។

IV. **ប្រសិទ្ធភាពនៃសេចក្តីជូនដំណឹង**

បទប្បញ្ញត្តិទាំងឡាយណាដែលមាននៅក្នុងសេចក្តីជូនដំណឹងលេខ ១៣ និង ១៦ ដែលមានខ្លឹមសារផ្ទុយពីបទប្បញ្ញត្តិនៃសេចក្តីជូនដំណឹងនេះត្រូវចាត់ទុកជានិរាករណ៍។

សេចក្តីជូនដំណឹងនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈមានសង្ឃឹមយ៉ាងមុតមាំថា សហព័ន្ធសហជីព សហជីពកម្មករ និយោជិត និយោជក និងអង្គភាពពាក់ព័ន្ធទាំងអស់ នឹងខិតខំសហការជាមួយក្រសួង ដើម្បីអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធិភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង សូត**

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋានការងារ
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សមាគមនិយោជក
-សហព័ន្ធសហជីព
" ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីផ្សព្វផ្សាយ"
-រាជកិច្ច
-ឯកសារ និងកាលប្បវត្តិ

ឧបសម្ព័ន្ធទី២

សេចក្តីជូនដំណឹងលេខ ០៣៣/០៨កប/ស.ជ.ណ

ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**កម្មវត្ថុ** : សំណើសុំប្តឹងជំទាស់ភាពជាតំណាងបំផុតរបស់សហជីព........................................

**យោង** : -ច្បាប់ស្តីពីការងារ

-ប្រកាសលេខ៣០៥ សកបយ.ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចចារជាសមូហភាពដើម្បីចុះអនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន

-សេចក្តីជូនដំណឹងលេខ០៣៣/០៨កប/ស.ជ.ណ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ ស្តីពីនីតិវិធីនៃការបញ្ជាក់ភាពជាតំណាង និងតំណាងបំផុត និងការបោះឆ្នោតសម្រេចភាពជាតំណាងបំផុតរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតថ្នាក់សហគ្រាស គ្រឹះស្ថាន

-លិខិតលេខ........... ចុះថ្ងៃទី........ ខែ..........ឆ្នាំ២០០............(លិខិតជូនដំណឹងអំពីការស្នើសុំភាពជាតំណាងបំផុតរបស់សហជីព) ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន**ឯកឧត្តមរដ្ឋមន្ត្រី**បានជ្រាបថា ខ្ញុំសូមស្នើសុំប្តឹងការជំទាស់និងការស្នើសុំភាពជាតំណាងបំផុតរបស់សហជីព............................................................................ ។

ខ្ញុំសូមផ្តល់ជូនព័ត៌មានមួយចំនួនដូចខាងក្រោម ÷

១-ឈ្មោះរូបវន្តបុគ្គលឬនីតិបុគ្គល (សហជីព) ដែលដាក់ពាក្យប្តឹងជំទាស់

..........................................................................................................................................

២-អាសយដ្ឋាន និងព័ត៌មានទំនាក់ទំនងរបស់ភាគីប្តឹងជំទាស់

..........................................................................................................................................

៣-ផលប្រយោជន៍ស្របច្បាប់របស់ភាគីប្តឹងជំទាស់នៅក្នុងពាក្យសុំបញ្ជាក់ភាពជាតំណាងបំផុត :

ក-តំណាងឱ្យសហជីព ដែលបានចុះបញ្ជិកានៅក្នុងសហគ្រាស ☐

ខ-សមាជិកគណៈកម្មការប្រឹក្សាការងារ ☐

គ-ផលប្រយោជន៍ផ្សេងៗទៀត ☐

៤-មូលហេតុឬហេតុផលសម្រាប់ការប្តឹងជំទាស់

ក-សហជីពដាក់ពាក្យសុំនោះពុំមែនជាសហជីពដែលមានភាពជាតំណាងបំផុត ☐

ខ-សហជីពដាក់ពាក្យសុំនោះក្លែងបន្លំពាក្យសុំរបស់ខ្លួន ☐

គ-សហជីពដាក់ពាក្យសុំនោះមិនមានភាពឯករាជ្យពីនិយោជក ☐

៥-សូមផ្តល់នូវភស្តុតាងដើម្បីគាំទ្រដល់ការជំទាស់នេះ ដូចខាងក្រោម ÷

ក-..........................................................................................................

ខ-..........................................................................................................

គ-..........................................................................................................

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំសូមស្នើសុំមេត្តាសម្រេចដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមរដ្ឋមន្ត្រី ដើម្បីបានភាពស្រប ច្បាប់ក្នុងការអនុវត្តតទៅ ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០....

(ហត្ថលេខា និងឈ្មោះ)

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ ២០០.....

បានឃើញ និងសូមស្នើសុំជំទាស់ដ៏ខ្ពង់ខ្ពស់អំពីឯកឧត្តមរដ្ឋមន្ត្រី

ប្រធានសហព័ន្ធសហជីព

(ករណីសហជីពនោះជាសមាជិករបស់សហព័ន្ធសហជីពណាមួយ)

ឧបសម្ព័ន្ធទី១

សេចក្តីជូនដំណឹងលេខ ០៣៣/០៨កប/ស.ជ.ណ

ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០...

**ប្រធានសហជីព**.................................................

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**កម្មវត្ថុ** : សំណើរសុំភាពជាតំណាង☐ ភាពជាតំណាងបំផុត☐ របស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត

**យោង** : -ច្បាប់ស្តីពីការងារ

-ប្រកាសលេខ៣០៥ សកបយ.ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចចារជាសមូហភាពដើម្បីចុះអនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន

-សេចក្តីជូនដំណឹងលេខ ០៣៣/០៨ កប/ស.ជ.ណ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ ស្តីពីនីតិវិធីនៃការបញ្ជាក់ភាពជាតំណាង និងតំណាងបំផុត និងការបោះឆ្នោតសម្រេចភាពជាតំណាងបំផុតរបស់អង្គការវិជ្ជាជីវៈនៃកម្មករ និយោជិតថ្នាក់សហគ្រាស គ្រឹះស្ថាន

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមរដ្ឋមន្ត្រីបានជ្រាបថាដើម្បីបានភាពជាតំណាងក្នុងការចរចាជាសមូហភាពដើម្បីចុះអនុសញ្ញារួម និងការធានាដោះស្រាយបញ្ហាផ្សេងៗ ជាមួយនិយោជក ខ្ញុំសូមគោរពស្នើសុំឯកឧត្តមរដ្ឋមន្ត្រីមេត្តាបញ្ជាក់ពី ភាពជាតំណាង☐ ភាពជាតំណាងបំផុត ☐ របស់សហជីពខ្ញុំបាទ/នាងខ្ញុំ។

ព័ត៌មានអំពីសហជីពមានដូចខាងក្រោម :

១-ឈ្មោះសហជីព :.......................................................................................................

២-បានចុះបញ្ជិកាលេខ................................ចុះថ្ងៃទី.......................................................

៣-ឈ្មោះសហព័ន្ធសហជីព :............................................................................................

៤-ឈ្មោះនិងអាសយដ្ឋានទំនាក់ទំនងរបស់សហជីព:.........................................................

.........................................................................................................................................

.........................................................................................................................................

៥-ឈ្មោះនិងអាសយដ្ឋានរបស់សហគ្រាសគ្រឹះស្ថាន :..........................................................................................

.........................................................................................................................................................

៦-វិស័យឧស្សាហកម្មដែលសហគ្រាសគ្រឹះស្ថានធ្វើសកម្មភាព :.........................................................................

.........................................................................................................................................................

.........................................................................................................................................................

៧-ក្របខ័ណ្ឌភូមិសាស្ត្រ ឬវិជ្ជាជីវៈរបស់អង្គការវិជ្ជាជីវៈ :..........................................................................

-ទូទាំងសហគ្រាស គ្រឹះស្ថាន ☐

-វិជ្ជាជីវៈខ្លះនៃសហគ្រាស គ្រឹះស្ថាន ☐ បរិយាយ :...................................................................

.........................................................................................................................

៨-ចំនួនសមាជិកសហជីព..................នាក់ និងចំនួនកម្មករសរុប...............នាក់ (ក្នុងក្របខ័ណ្ឌភូមិសាស្ត្រឬវិជ្ជាជីវៈរបស់អង្គការវិជ្ជាជីវៈនិងវិជ្ជាជីវៈ)

៩-ការបង់វិភាគទាន :

-បង់ដោយផ្ទាល់ដៃ ☐ ចំនួន.........នាក់ ស្មើនឹង...........ភាគរយនៃសមាជិក

-បង់តាមរយៈនិយោជក ☐ ចំនួន.........នាក់ ស្មើនឹង...........ភាគរយនៃសមាជិក

១០-កម្មវិធីការងាររបស់សហជីព :

.........................................................................................................................

.........................................................................................................................

.........................................................................................................................

១១-ជូនភ្ជាប់មកជាមួយនូវ :

-ច្បាប់ថតចំលងវិញ្ញាបនប័ត្រចុះបញ្ជិកា

-ច្បាប់ចម្លងបញ្ជីឈ្មោះសមាជិក និងចំនួនកម្មករ និយោជិតសរុបដូចបញ្ជាក់ក្នុងចំណុច៨

-ច្បាប់ចម្លងបញ្ជីបង់ប្រាក់ភាគទានរបស់សមាជិកសហជីព ទោះបីដោយផ្ទាល់ក្តី ឬតាមរយៈនិយោជកក្តី ដូចមានបញ្ជាក់ក្នុងចំណុច៩

-ភស្តុតាង និងឯកសារផ្សេងៗ ។

អាស្រ័យដូចបានជំរាបជូនខាងលើ ខ្ញុំសូមស្នើសុំសេចក្តីបញ្ជាក់ដ៏ខ្ពង់ខ្ពស់ ពីឯកឧត្តមរដ្ឋមន្ត្រី ដើម្បីបានភាពស្របច្បាប់ក្នុងការអនុវត្តតទៅ ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

(ហត្ថលេខា និងឈ្មោះ)

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ ២០០.....

បានឃើញ និងសូមស្នើសុំសេចក្តីបញ្ជាក់ដ៏ខ្ពង់ខ្ពស់អំពីឯកឧត្តមរដ្ឋមន្ត្រី

ប្រធានសហព័ន្ធសហជីព

(ករណីសហជីពនោះជាសមាជិករបស់សហព័ន្ធសហជីពណាមួយ)